សុន្ទរកថា

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្លែងក្នុង

ពិធីបិទសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ ២០២២

ក្រោមប្រធានបទ «ការស្តារកម្ពុជាឡើងវិញ ពីវិបត្តិនៃជំងឺកូវីដ-១៩ ៖ ការអភិវឌ្ឍប្រកបដោយនិរន្តរភាព បន្ទាប់ពីជំងឺកូវីដ-១៩»

សណ្ឋាគារសុខាភ្នំពេញ, ថ្ងៃទី ៦ ខែតុលា ឆ្នាំ ២០២២

(ម៉ោង ១៦:៤៥-១៧:១៥)

- ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី និង ភ្ញៀវកិត្តិយសទាំងអស់, ជាទីរាប់អាន!

ថ្ងៃនេះ, ខ្ញុំពិតជាមានកិត្តិយស និង សេចក្តីសោមនស្ស ដោយបានចូលរួមថ្លែងសុន្ទរកថា ក្នុងពិធីបិទ **សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ ២០២២** ក្រោមប្រធានបទ **«ការស្តារកម្ពុជាឡើងវិញ ពីវិបត្តិនៃជំងឺកូវីដ-១៩ ៖ ការអភិវឌ្ឍប្រកបដោយនិរន្តរភាព បន្ទាប់ពីជំងឺកូវីដ-១៩»** ដែលត្រូវបានផ្តួចផ្តើម និង រៀបចំឡើងដោយ **វិទ្យាស្ថាន** CDRI ក្រោមកិច្ចសហការជាមួយស្ថាប័នជាដៃគូ និង ដោយមានការចូលរួមគាំទ្រពីវិស័យឯកជន ផងដែរ ។ ខ្ញុំសូមថ្លែងអំណរគុណ ចំពោះឯកឧត្តមបណ្ឌិត **ម៉ី កល្យាណ** ដែលបានផ្តល់នូវរបាយការណ៍បូកសរុបលទ្ធផលនៃការពិភាក្សារបស់អង្គសន្និបាតយ៉ាងគ្រប់ជ្រុងជ្រោយ ។ ប្រធានបទនៃការពិភាក្សារបស់យើងនាថ្ងៃនេះ ពិតជាមានភាពពាក់ព័ន្ធ និង មានសារៈសំខាន់ ស្របពេលដែលកម្ពុជាកំពុងសម្លឹងឆ្ពោះទៅរកការអភិវឌ្ឍ ប្រកបដោយចីរភាព, ភាពធន់រឹងមាំ និង បរិយាបន្ន ។ ក្នុងន័យនេះ, ខ្ញុំសូមវាយតម្លៃខ្ពស់ ចំពោះការចូលរួមយ៉ាងផុសផុល តាមរយៈការចែករំលែកនូវមតិយោបល់, ទស្សនទាន និង បទពិសោធ ប្រកបដោយស្មារតីស្ថាបនា

សម្រាប់ជាឧត្តមប្រយោជន៍ ដើម្បីជានាការស្តារសេដ្ឋកិច្ចឡើងវិញបានឆាប់រហ័ស ជាពិសេស សម្រេចឱ្យបាននូវចក្ខុវិស័យកម្ពុជា ក្នុងការប្រែក្លាយខ្លួនជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និង ជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០ ។

ឆ្លៀតឱកាសដ៏ប្រពៃនេះ, ខ្ញុំសូមជម្រាបជូនអង្គសន្និសីទផងដែរថា ចំពោះការជំរុញការស្តារកិច្ចអភិវឌ្ឍកម្ពុជាឡើងវិញ ប្រកបដោយនិរន្តរភាព ពីវិបត្តិនៃជំងឺកូវីដ-១៩ ក្រោយវិបត្តិនៃជំងឺកូវីដ-១៩, រាជរដ្ឋាភិបាលបានប្រកាន់ខ្ជាប់ នូវស្មារតីបុរេសកម្ម, ប្រុងប្រយ័ត្ន និង គណនេយ្យភាពខ្ពស់ ដោយបានគិតគូរជាយុទ្ធសាស្ត្រ និង មានភាពប្រទាក់ក្រឡាគ្នា ក្នុងការដាក់ចេញនូវវិធានការរដ្ឋបាល, ការអនុវត្តកិច្ចការកែទម្រង់មុតស្រួច និង គោលនយោបាយសំខាន់ៗនានា ។ ជាក់ស្តែង, រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រ និង គោលនយោបាយសំខាន់ៗជាបន្តបន្ទាប់ ដូចជា៖ **ក្របខណ្ឌគោលនយោបាយសង្គម-សេដ្ឋកិច្ចឌីជីថលកម្ពុជា ២០២១-២០៣៥; ក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធីស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣; យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និង កាបូបកម្ពុជា ២០២២-២០២៧** ជាដើម ។

តាមរយៈភាពបុរេសកម្ម, ការអនុវត្តនូវគោលនយោបាយ និង ការកែទម្រង់នានា ក្នុងគោលបំណងប្រែក្លាយវិបត្តិទៅជាកាលានុវត្តភាព, យើងអាចវាយតម្លៃបានថា វិធានការនានាដែលត្រូវបានអនុវត្តដោយរាជរដ្ឋាភិបាល ពិតជាបានចូលរួមចំណែកក្នុងកាត់បន្ថយផលប៉ះពាល់ពីវិបត្តិកូវីដ-១៩, ទាំងលើទិដ្ឋភាពនៃការការពារអាយុជីវិត និង ការរក្សាលំនឹងជីវភាពរស់នៅរបស់ប្រជាជន, និង ទាំងការធានារក្សាលំនឹងនៃកិច្ចដំណើការជាប្រក្រតី នៃធុរកិច្ចរបស់វិស័យឯកជន, ក៏ដូចជាការជួយជំរុញកំណើនសេដ្ឋកិច្ចឡើងវិញក្នុងទម្រង់ជាអក្សរ V ក្នុងអាត្រាមួយខ្ពស់គួរសម, ក្នុងរង្វង់ប្រមាណ ៥% ក្នុងឆ្នាំ ២០២២ និង ៦% ក្នុងឆ្នាំ ២០២៣ ។ ជាមួយគ្នានេះដែរ, រចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជាក៏បានបង្ហាញនូវភាពធន់, ភាពបត់បែន និង ឆ្លើយតបបានលឿនទៅនឹងវិបត្តិនាពេលកន្លងមក ។ លទ្ធផលល្អទាំងនេះបានឆ្លើយតប ប្រកបដោយប្រសិទ្ធភាព ទៅនឹងគោលបំណងរបស់រាជរដ្ឋាភិបាល ក្នុងការរៀបចំនូវវិថីនៃការអភិវឌ្ឍនាពេលអនាគត ។

- ***ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!***

ដូចអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កាលពីព្រឹកមិញនេះ, ខណៈដែលការរាតត្បាតនៃជំងឺកូវីដ-១៩ បានថមថយ, យើងមិនត្រូវមើលរំលងនូវបញ្ហាប្រឈមធំៗផ្សេងទៀត ដែលបាន និង កំពុងកើតមានឡើងដំណាលគ្នានោះទេ ដូចជា ការបន្តអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន, ការប្រកួតប្រជែងផ្នែកភូមិសាស្ត្រនយោបាយ រវាងបណ្តាមហាអំណាច, ការ-កើនឡើងនៃសម្ពាធអតិផរណា, ការបែកខ្ញែកនៃច្រវាក់ផ្គត់ផ្គង់តំបន់ និង សកល និង ការ-ប្រែប្រួលអាកាសធាតុ ជាដើម ។ ជាការពិត, បញ្ហាប្រឈមទាំងនេះមានសភាពកាន់តែស្រួចស្រាវ ដែលអាចបន្ទច់បង្អាក់ដល់ការងើបឡើងវិញនៃសេដ្ឋកិច្ចសកល, សាមគ្គីភាព និង កិច្ចសហការអន្តរជាតិ ដែលកំពុងមានលក្ខណៈផុយស្រួយ និង ងាយបែកខ្ញែកស្រាប់ ។

ប៉ុន្តែ, យើងក៏បានកត់សម្គាល់ឃើញផងដែរថា នៅក្នុងបរិបទសកលដែលកំពុងវិវត្តកាន់តែស្មុគស្មាញទៅនេះ ក៏មាននិន្នាការវិជ្ជមានមួយចំនួន ដែលអាចផ្តល់កាលានុវត្តភាពសម្រាប់ការចូលរួមចំណែកជំរុញចលនាសេដ្ឋកិច្ចសកលឱ្យងើបឡើងវិញ ប្រកបដោយភាពធន់ និង បរិយាបន្ន ដូចជា ការចាប់យកប្រយោជន៍ពីការវិវត្តយ៉ាងឆាប់រហ័សនៃបរិវត្តកម្មឌីជីថល និង ឌីជីថលូបនីយកម្ម ក្នុងវិស័យសង្គម និង វិស័យសេដ្ឋកិច្ច, ការបង្កើនការយក-ចិត្តទុកដាក់លើការជំរុញការធ្វើអន្តរកាលថាមពល (Energy Transition), ការបង្កើនការវិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបៃតង និង ការអភិវឌ្ឍហិរញ្ញវត្ថុ ប្រកបដោយចីរភាព (Sustainable Finance) ជាដើម ។ ក្នុងន័យនេះ, កម្ពុជា ក៏ដូចជាពិភពលោកទាំងមូល ត្រូវផ្តល់អាទិភាពលើកិច្ចការទាំងនេះ និង ត្រូវកំណត់នូវទិសដៅថ្មី ឱ្យស្របតាមនិន្នាការ និង ការផ្លាស់ប្តូរនៃរចនាសម្ព័ន្ធសកល សម្រាប់ការស្តារ និង ជំរុញការងើបឡើងវិញ នៃកំណើនសេដ្ឋកិច្ច ពិសេស ក្នុងការអភិវឌ្ឍប្រកបដោយចីរភាព, បរិយាប័ន្ន និង ភាពធន់រឹងមាំសម្រាប់រយៈពេលមធ្យម និង វែង ។

ឆ្លៀតក្នុងឱកាសនេះ, ខ្ញុំសូមធ្វើការសង្កត់ធ្ងន់លើសារៈសំខាន់ នៃទិសដៅកិច្ចការមួយចំនួន ដែលត្រូវបានលើកឡើង នៅក្នុងសន្និសីទនាថ្ងៃនេះ ដូចខាងក្រោម ៖

ទី ១. ស្របតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅក្នុងពិធីបើកសន្និសីទ នាព្រឹកនេះ, រាជរដ្ឋាភិបាលនឹងផ្ដល់អាទិភាពខ្ពស់ដល់ការពង្រឹងភាពធន់ និង ចីរភាពនៃការអភិវឌ្ឍ ដោយឈរលើគោលការណ៍កំណត់យក «**មនុស្សជាអាទិភាពខ្ពស់**» តាមរយៈការលើកកម្ពស់ការវិនិយោគលើវិស័យសុខាភិបាល, វិស័យអប់រំ, ការអភិវឌ្ឍជំនាញ និង ការពង្រឹងប្រព័ន្ធគាំពារសង្គម ដើម្បីធានាឱ្យធនធានមនុស្ស ប្រកបដោយចំណេះ និង ជំនាញរបស់កម្ពុជា ក្លាយជាធនធានចន្ទល់ដ៏សំខាន់ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច;

ទី ២. បន្ថែមពីលើមនុស្សដែលជាអាទិភាពទី ១, ផ្លូវ, ភ្លើង និង ទឹក នៅតែជាអាទិភាពក្នុងការអភិវឌ្ឍនាពេលអនាគត ។ ជាមួយគ្នានេះដែរ, យើងទាំងអស់គ្នាបានដឹងហើយថា ជំងឺកូវីដ-១៩ បានធ្វើឱ្យសម្ទុះនៃឌីជីថលូបនីយកម្ម កើនឡើងកាន់តែខ្លាំង ដែលការណ៍នេះបាន និង កំពុងបង្កើតទាំងបញ្ហាប្រឈម និង កាលានុវត្តភាពថ្មីៗ ។ ក្នុងន័យនេះ, ជាទិសដៅថ្មីនៃការអភិវឌ្ឍ, យើងត្រូវគិតគូរបន្ថែមដល់ការគ្រប់គ្រង និង ការទាញប្រយោជន៍ឱ្យអស់សក្ដានុពលពីឌីជីថលូបនីយកម្ម ។

ទី ៣. ស្របអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចតេជោនាយករដ្ឋមន្ត្រី** ក៏ដូចជាលទ្ធផលនៃកិច្ចពិភាក្សានៅក្នុងអង្គសិក្ខាសាលានេះ, កម្ពុជាត្រូវធ្វើការកែទម្រង់ស៊ីជម្រៅឱ្យកាន់តែខ្លាំង ជាពិសេស ការប្ដេជ្ញាដោះស្រាយឱ្យខាងតែបាន នូវបញ្ហាប្រឈមជារចនាសម្ព័ន្ធ ដើម្បីពង្រឹងបន្ថែមទៀត នូវវិស័យដែលជាចន្ទល់នៃសេដ្ឋកិច្ច នាពេលបច្ចុប្បន្ន ក៏ដូចជាធ្វើពិពិធកម្មរចនាសម្ព័ន្ធសេដ្ឋកិច្ចទៅវិស័យថ្មីៗ ដែលមានសក្ដានុពលបន្ថែមទៀត ។ ជាមួយគ្នានេះ, កម្ពុជាត្រូវបន្តខិតខំពន្លឿនការធ្វើសមាហរណកម្មសេដ្ឋកិច្ច និង ពាណិជ្ជកម្មជាមួយបណ្ដាប្រទេសក្នុងតំបន់ និង នៅជុំវិញពិភពលោក, ចាប់យកប្រយោជន៍ឱ្យអស់លទ្ធភាព ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនីមួយៗ, ទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស ក្នុងសកម្មភាព-វិស័យដែលមានតម្លៃបន្ថែមខ្ពស់ និង ប្រើប្រាស់បច្ចេកវិទ្យាទំនើប, ជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តឌីជីថល និង ថាមពល និង បន្តធ្វើឱ្យប្រសើរឡើងលើវិស័យឡូជីស្ទីក និង កិច្ចសម្រួលពាណិជ្ជកម្ម;

ទី ៤. ជំងឺកូវីដ-១៩ ក៏ដូចជាបញ្ហាប្រឈមផ្សេងទៀត បានជះឥទ្ធិពលយ៉ាងខ្លាំងដល់ប្រជាជនក្រីក្រ និង ជនងាយរងគ្រោះ ដែលធ្វើឱ្យគម្លាតសង្គមរីកកាន់តែធំឡើង ពិសេស បញ្ហា

ដែលបន្សល់ទុកជាស្លាកស្នាម (scarring effects) ពីការរាតត្បាតនៃជំងឺកូវីដ-១៩ ដែលធ្វើឱ្យផលិតភាពពលកម្មមានការធ្លាក់ចុះ ។ ក្នុងស្មារតីនេះ, ការអភិវឌ្ឍប្រកបដោយចីរភាព និង បរិយាបន្ន តម្រូវឱ្យផ្តោតអាទិភាពខ្ពស់លើការកសាងប្រព័ន្ធសន្តិសុខសង្គមមួយប្រកបដោយភាពរឹងមាំ និង ឆ្លើយតបទៅគ្រប់ដំណាក់កាល នៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច;

ទី ៥. ក្នុងបរិការណ៍នៃការកើនឡើងកម្តៅ នៃការប្រកួតប្រជែងផ្នែកភូមិសាស្ត្រនយោបាយរវាងបណ្តាមហាអំណាច, ការធានាឱ្យបាននូវស្ថិរភាព និង សុខសន្តិភាព, ផ្នែកសង្គម-សេដ្ឋកិច្ច និង នយោបាយ, គឺជាបុរេលក្ខខណ្ឌយ៉ាងសំខាន់មិនអាចខ្វះបាន សម្រាប់ការបន្តការអភិវឌ្ឍ ប្រកបដោយចីរភាព និង បរិយាបន្ន ។ ក្នុងបរិបទនេះ, កម្ពុជាត្រូវបន្តពង្រឹងស្ថិរភាព និង សុខសន្តិភាពផ្ទៃក្នុង ព្រមទាំងចូលរួមយ៉ាងសកម្ម ក្នុងការ-ពង្រឹងយន្តការពហុភាគីនិយម និង ការសហការជាមួយដៃគូក្នុងតំបន់ និង ជុំវិញពិភពលោក ដើម្បីដោះស្រាយបញ្ហាប្រឈមនានា ដោយសន្តិវិធី; និង

ទី ៦. ដូចប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី**, ធនធានហិរញ្ញវត្ថុពិតជាមានសារៈសំខាន់ណាស់, ម៉្យាង, ដើម្បីដោះស្រាយបញ្ហាដែលជាស្លាកស្នាមពីវិបត្តិនៃជំងឺកូវីដ-១៩, ជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ និង ស្តារមូលដ្ឋានអភិវឌ្ឍសង្គម-សេដ្ឋកិច្ចឡើងវិញ ដែលប្រការនេះទាមទារឱ្យយើង ផ្តោតជាចម្បងលើ៖ (១)-ការអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗ ជាពិសេស កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ២០១៦-២០២៥; និង (២)-ការបង្កើនការវិនិយោគលើវិស័យដែលផ្តល់ផលរយៈពេលវែង; និងម៉្យាងទៀត, ដើម្បីត្រៀមទប់ទល់នឹងសភាពការណ៍មិនប្រាកដប្រជា សំដៅបន្តធានាឱ្យបាននូវមាគ៌ាអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ក្នុងគន្លងនៃប្រក្រតីភាពថ្មី ដែលមានភាពធន់រឹងមាំទល់នឹងវិបត្តិ ។ ជាមួយនឹងការគិតគូរនេះ, រាជរដ្ឋាភិបាលនឹងបន្តផ្តោតលើការងារជាអាទិភាព ៣ យ៉ាង រួមមាន៖ (១)-កិច្ចប្រឹងប្រែងកៀរគរចំណូលពីគ្រប់ប្រភព ឱ្យអស់សក្តានុពល; (២)-ការ-តម្រង់ការវិភាជថវិកាជាតិ ឱ្យបានត្រឹមត្រូវ និង ចំទិសដៅ ទន្ទឹមនឹងការបន្តលើកកម្ពស់ថែមទៀត នូវប្រសិទ្ធភាពនៃការអនុវត្តថវិកាក្នុងគ្រប់ដំណាក់កាល ដើម្បីធានា

«**តម្លៃនៃលុយ**»; និង (៣)-ការបន្តជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ប្រកបដោយចីរភាព ជាមួយនឹងការលើកទឹកចិត្តដល់ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ពិសេសវិស័យឯកជន ។

- ***ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!***

មុននឹងបញ្ចប់, ខ្ញុំសូមជម្រាបអង្គសន្និសីទបន្ថែមថា ខណៈដែលកម្ពុជាកំពុងពង្រឹងមូលដ្ឋានអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចឱ្យកាន់តែរឹងមាំ ដើម្បីបោះជំហាននៅលើគន្លងអភិវឌ្ឍន៍ថ្មី ផ្សារភ្ជាប់នឹងការផ្លាស់ប្តូរនិម្មាបនកម្មសេដ្ឋកិច្ច និង ពាណិជ្ជកម្មសកល, រាជរដ្ឋាភិបាល បាន និង កំពុងបង្កើនការយកចិត្តទុកដាក់ទ្វេដង លើការលើកកម្ពស់នូវភាពធន់ទៅនឹងវិបត្តិ ដោយផ្តោតលើការពង្រឹងប្រព័ន្ធរដ្ឋបាលសាធារណៈមួយ ដែលកាន់តែស្អាតស្អំ, ឆ្លាតវៃ និង មានសមត្ថភាពខ្លាំងពូកែ ដើម្បីអាចគ្រប់គ្រង និង ដោះស្រាយបញ្ហាសង្គម-សេដ្ឋកិច្ចនានា ប្រកបដោយប្រសិទ្ធភាពខ្ពស់ ក្នុងរយៈពេលវែង, និង ការបន្តខិតខំព្យាយាមឥតស្រាកស្រាន្ត ដើម្បីដោះស្រាយបញ្ហាប្រឈមនានា សំដៅលើកកម្ពស់ការអភិវឌ្ឍ និង ការចូលរួមរបស់វិស័យឯកជន ដើម្បីពង្រឹងភាពប្រកួតប្រជែង និង ជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច ។

ជាមួយនឹងការចូលរួមយ៉ាងសកម្មរបស់ **ឯកឧត្តម**, **លោកជំទាវ**, **អ្នកឧកញ៉ា**, **ឧកញ៉ា**, **លោក**, **លោកស្រី** និង ជាពិសេស ក្រោមការដឹកនាំដ៏ប៉ិនប្រសប់, ភាពប្រាកដនិយម និង ប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី**, ខ្ញុំជឿជាក់យ៉ាងមុតមាំថា កម្ពុជានឹងអាចយកឈ្នះលើគ្រប់ឧបសគ្គ និង សម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និង បរិយាបន្ន ជូនដល់ប្រជាជាតិកម្ពុជាយើង ។

ជាទីបញ្ចប់, ខ្ញុំសូមជូនពរ **ឯកឧត្តម**, **លោកជំទាវ**, **អ្នកឧកញ៉ា**, **ឧកញ៉ា**, **លោក**, **លោកស្រី** និង **ភ្ញៀវកិត្តិយសទាំងអស់**, ប្រកបដោយសុខភាពល្អបរិបូរណ៍, សម្រេចជោគជ័យគ្រប់ភារកិច្ច ព្រមទាំងទទួលបាននូវវិបុលភាព និង សុភមង្គលក្នុងក្រុមគ្រួសាររៀងៗខ្លួន នៅក្រោមម្លប់ដ៏ត្រជាក់ត្រជុំនៃសុខសន្តិភាពជាយូរអង្វែងតទៅ ។

ខ្ញុំសូមប្រកាសបិទ **សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ ២០២២** ក្នុងពេលនេះ ៕

សូមអរគុណ!